# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ** **រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩**

លេខ: ១៧ សជណ

## សេចក្តីជូនដំណឹង

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានកិត្តិយស សូមជម្រាបជូនជាដំណឹងដល់អាជីវករ សិល្បករ សិល្បការិនី អ្នកចម្រៀង ក្រុមកំប្លែង ក្រុមតន្ត្រីសម័យ អ្នកប្រកបរបរជួលធុងបាស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា ៖ កន្លងមកក្រសួងសង្កេតឃើញថា នៅតាមកន្លែងលក់កាសែ្សតចម្រៀង ស៊ីឌី នៅតាមកន្លែងប្រគុំតន្ត្រី សាធារណៈ (Concert) កន្លែងប្រគុំតន្ត្រីកំដរក្នុងពិធីបុណ្យផ្សេងៗ-អាពាហ៍ពិពាហ៍-ជប់លៀង និងកន្លែងចាក់ចម្រៀង ប្រើធុងបាស់ បានយកបទចម្រៀង ដែលមានខ្លឹមសារអសុរស អាសអាភាសមិនគួរគប្បី ទៅច្រៀង និងផលិតជាស៊ីឌី ឬ កាសែ្សត ដាក់លក់ជាសាធារណៈ ធ្វើឱ្យប៉ះពាល់ដល់ប្រពៃណី ទំនៀមទម្លាប់វប្បធម៌ កិត្តិយសសង្គមយ៉ាងធ្ងន់ធ្ងរ ជាពិសេសប៉ះពាល់ដល់កិត្តិយសនារីខ្មែរយើង និងជាបច្ច័យនាំឱ្យមានអំពើអនាចារកើតមានឡើងជាបន្តបន្ទាប់នៅទូទាំង ព្រះរាជាណាចក្រកម្ពុជា ។ បទចម្រៀងទាំងនោះមានជាអាទិ : **សុំច្បាប់មេឃុំយកស្រូវទៅបុក ក្រពើមិនធាន់ធំ ខ្លុយតាចៀន ខ្លុយបងចាច ខ្លុយចាំង... ។**

អាស្រ័យហេតុនេះ ដើម្បីការពារ និងរក្សាទំនៀមទម្លាប់ ប្រពៃណីដ៏ល្អផូរផង់របស់ជាតិយើងដែលមានតាំងពីបុរាណកាលមក សូមអាជីវករ សិល្បករ សិល្បការិនី អ្នកចម្រៀង ក្រុមកំប្លែង ក្រុមតន្ត្រីសម័យ អ្នកប្រកបរបរ ជួលធុងបាស់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា បញ្ឈប់ជាបន្ទាន់រាល់ការច្រៀង ការប្រគុំតន្ត្រី ការចាក់និងការលក់ នូវបទចម្រៀងដូចបានរៀបរាប់ខាងលើចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

ក្នុងករណីពិនិត្យឃើញ អាជីវករ សិល្បករ សិល្បការិនី អ្នកចម្រៀង ក្រុមកំប្លែង ក្រុមតន្ត្រីសម័យ អ្នកប្រកបរបរជួលធុងបាស់ នៅតែបន្តសកម្មភាពខាងលើនេះទៀត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងមានវិធានការតាមផ្លូវច្បាប់ជាធរមាន ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សង្ឃឹមជឿជាក់ថា អាជីវករ សិល្បករ សិល្បការិនី អ្នកចម្រៀង ក្រុមកំប្លែង ក្រុមតន្ត្រីសម័យ អ្នកប្រកបរបរជួលធុងបាស់ទាំងអស់ នឹងយកអស់ស្មារតី អនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ និងថ្លៃថ្នូរ ។

**រដ្ឋមន្ត្រី**

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ហ៊ឹម ឆែម**

**ចម្លងជូន**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-ក្រសួងមហាផ្ទៃ
-ក្រសួងយុត្តិធម៌
-ក្រសួងព័ត៌មាន
-សាលាក្រុងរាជធានីភ្នំពេញ
-គ្រប់សាលាខេត្ត
-គ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ: លោក ឈឹម ទីណា